Übersetzung eines Schreibens von: Uwe Kekeritz, MdB

An: Bundesminister Dr. Gerd Müller

Datiert: 04. Dezember 2014

អ៊ូវើ ខេខឺរីត្ស
Uwe Kekeritz
សមាជិកសភាសហព័ន្ធអាល្លឺម៉ង់
សមាជិកគណកម្មាធិការសហប្រតិបត្តិការ
សេដ្ឋកិច្ច និងអភិវឌ្ឍន៍
អ្នកនាំពាក្យផ្នែកនយោបាយអភិវឌ្ឍន៍
ក្រុមគណបក្ស Bündnis 90 / Die Grünen នៅក្នុងសភាសហព័ន្ធ

Platz der Republik 1
11011 Berlin
Telefon: +49 30 227-77346
Fax: +49 30 227-76346
Mail: Uwe.Kekerlitz@bundestag.de

Uwe Kekeritz MdB, Platz der Republik 1, 11011 Berlin

ជូនចំពោះលោក
បណ្ឌិត ហ្គែត មូល័រ  Dr. Gerd Müller ជារដ្ឋមន្ត្រីសហព័ន្ធ
ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច
Bundesministerium für Wirtschaftliche Zusammenarbeit
Stresemannstr. 94
10963 Berlin

ប៊ែរលីន ថ្ងៃទី ៤ ធ្នូ ២០១៤

**វិធានការនយោបាយអភិវឌ្ឍន៍សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់នៅទូទាំងពិភពលោក របស់ឧស្សាហកម្មវាយនភ័ណ្ឌ**

លោករដ្ឋមន្ត្រីសហព័ន្ធជាទីគោរព

នៅក្នុងឱកាសនៃការបង្ហាញអំពីសម័ន្ធភាពផ្នែកវាយនភ័ណ្ឌ  លោកបានប្រកាសថា នឹងតម្រង់មុខព្រួញសហប្រតិបត្តិការអភិវឌ្ឍន៍សំដៅទៅរកឧស្សាហកម្មវាយនភ័ណ្ឌនៅតាមប្រទេសផលិតកម្មទាំងឡាយ។ ខ្ញុំសូមធ្វើការគាំទ្រជាគោលការណ៍ចំពោះការប្រកាសជំហរនេះ ប៉ុន្តែទន្ទឹមនឹងនេះដែរ ខ្ញុំក៏សូមអោយលោកមេត្តាធ្វើការអធិប្បាយអំពីគម្រោងផែនការរបស់លោកអោយខ្ញុំបានដឹងផង។

តើការប្រកាសជំហររបស់លោកនឹងត្រូវអនុវត្តជាក់ស្តែងតាមបែបណា? តើក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចចាត់ទុកវិធានការណាថា ជាវិធានការសមស្រប? តើក្រសួងមានបានបោះជំហរជាក់ស្តែងសំដៅទៅរកទិសដៅនេះហើយឬនៅ? ប្រសិនបើបានធ្វើដូច្នេះហើយ តើបានធ្វើអ្វីខ្លះ? តើលោកនឹងទាញបញ្ចូលអ្នកពាក់ព័ន្ធប្រយោជន៍ណាខ្លះអោយចូលរួមក្នុងការអភិវឌ្ឍន៍ និងការអនុវត្តវិធានការដែលបានគ្រោងទុកនោះ ហើយតើប្រទេសជាដៃគូណាខ្លះនឹងត្រូវជាប់ពាក់ព័ន្ធទៅនឹងផែនការរបស់លោកនោះ? តើនៅពេលអញ្ជើញទៅធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាលោករដ្ឋលេខាធិការឃីតឈើល (Kitschel) ជាដើមបានធ្វើសកម្មភាពគាំទ្រដល់គម្រោងផែនការនេះហើយឬនៅ? ប្រសិនជាបានធ្វើហើយ តើក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចគ្រោងធ្វើអ្វីជាក់ស្តែង ដើម្បីធ្វើអោយលក្ខខណ្ឌការងារមានលក្ខណៈប្រសើរជាងមុននៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជា?

អ្នកពាក់ព័ន្ធប្រយោជន៍នៅតាមប្រទេសផលិតកម្មទាំងឡាយតែងតែសុំអោយខ្ញុំរក្សានូវសម្ពាធទៅលើរដ្ឋាភិបាលពាក់ព័ន្ធ ដោយសាររដ្ឋាភិបាលទាំនោះពុំព្រមធ្វើតាមការទាមទាររបស់ប្រជាពលរដ្ឋរបស់ខ្លួនឡើយ។ ដូច្នេះហើយបានជាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ត្រូវតែប្រើប្រាស់នូវទម្ងន់នយោបាយរបស់ខ្លួន ដើម្បីធ្វើការពិភាក្សាជាមួយនឹងរដ្ឋាភិបាលនៃប្រទេសជាដៃគូនានា ដើម្បីសម្រេចអោយបាននូវការកែលំអផ្នែកសភាពការណ៍ច្បាប់ក៏ដូចជាការអនុវត្តបទដ្ឋានផ្នែកសង្គមកិច្ច ផ្នែកបរិដ្ឋានដែលមានលក្ខណៈប្រសើរ ជាងមុននោះដែរ។

សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលជាប្រទេសនាំទំនិញចេញ និងជាមាតុប្រទេសនៃរបបផ្សារសេរីដែលគិតពីសង្គមនោះ អាចធ្វើការពិគ្រោះផ្តល់មតិជូនដល់រដ្ឋាភិបាលនៃប្រទេសផលិតកម្មនានាបានទៅតាមសមត្ថភាពជំនាញ និងទៅតាមលក្ខណៈ ដែលអាចអោយគេជឿទុកចិត្តបាន។ សកម្មភាពរបស់មូលនិធិនយោបាយនានានៅតាមប្រទេសផលិតកម្មទាំងឡាយក៏អាចជួយជម្រុញដំណើរការនេះអោយមានប្រសិទ្ធភាព និងអាចជួយឧបត្ថម្ភដល់អ្នកពាក់ព័ន្ធប្រយោជន៍នានាបាន ហើយតាមរយៈនេះនឹងអាចសម្រេចបាននូវការកែលំអយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋនៅទីនោះ។

ដោយគោរព

អ៊ូវើ ខេខីរីត្ស